ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧. សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យការដូរឆ្នាំកំណើត និងកាំប្រាក់របស់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១ៈ** បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យការដូរឆ្នាំកំណើត និងកាំប្រាក់ របស់មន្ត្រីរាជការដែលមាន សមាសភាពដូចខាងក្រោម :

www.pheakdeylaw.com

១- ឯកឧត្តម ទើង សិរីវុឌ្ឍ ទេសរដ្ឋមន្ត្រី ប្រធាន

២-ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ( បំរុងឯកឧត្តម ទោភ សុធារិន អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សមាជិក

៣-ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

៤-ឯកឧត្តម ម៉ៅ ហុងលី អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល សមាជិក អចិន្ត្រៃយ៍

៥-តំណាងក្រសួង ស្ថាប័នដែលគ្រប់គ្រងមន្ត្រីសាមី សមាជិក ។

**ប្រការ ២** : គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យការដូរឆ្នាំកំណើត និងកាំប្រាក់ របស់មន្ត្រីរាជការ មានតួនាទី និង ភារកិច្ចដូចតទៅ :

- ពិនិត្យ ផ្ទៀងផ្ទាត់ លើឯកសារការដូរឆ្នាំកំណើត និងកាំប្រាក់របស់មន្ត្រីរាជការ
- ពិនិត្យស្រាវជ្រាវឯកសារពាក់ព័ន្ធពតិមានមន្ត្រីរាជការស៊ីវិលក្នុងករណីចាំបាច់
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល តាមរយៈប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**ប្រការ ៣** : សមាសភាព គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យការដូរឆ្នាំកំណើត និងកាំប្រាក់ របស់មន្ត្រីរាជការ អាចធ្វើការកែសម្រួលបាននៅពេលមានតម្រូវការចាំបាច់ ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃទីចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៣ ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួងស្ថាប័ន*
- *ដូចប្រការ ៤ √*
- *ឯកសារ-កាលប្បវត្តិ*